# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**

លេខ ០៣៤១ ព.ណ.ក.ម.ស

ថ្ងៃ ពុធ ៨កើត ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៨

**<u>ជម្រាបមក</u>**

**លោក/លោកស្រីប្រធានក្រុមហ៊ុន ធី សប ៦.ក**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលសម្ភារៈ និងគ្រឿងអគ្គិសនីដូចជា៖ ក្បាល(ដុំ)សម្រាប់បំបែក ឬបែងចែក [ឧបករណ៍ដំណើរការទិន្នន័យ] ឧបករណ៍ឆ្លុះអក្សរ និងលេខសម្ងាត់ [ឧបករណ៍ដំណើរការទិន្នន័យ] ឧបករណ៍ផ្ទុកព័ត៌មាន (USB) ឧបករណ៍ជំនួយផ្តិតមេដៃផ្ទាល់ខ្លួន (PDAs) ឧបករណ៍តន្ត្រីអេឡិចត្រូនិច ឧបករណ៍អាចទាញយកព័ត៌មាន សម្ភារៈបិទពីលើសម្រាប់ស្មាតហ្វូន ផ្លាស់ស្ទីកបិទសម្រាប់ការពារស្មាតហ្វូន ធុងបាស កាសស្តាប់ត្រចៀក ឧបករណ៍បង្កូម ឬជួយសម្លេង ឧប្លើរ វ៉ែនតាមើលវីដេអូដូចឃើញរូបភាពពិតៗ ឧបករណ៍សារ៉េសម្លេង ឧបករណ៍ដូត ញុក ខ្នាស់ ថតរូបផ្ទាល់ខ្លួន [ដងកាន់សម្រាប់ថតរូប] ម៉ាស៊ីនថតឃើញស្រមោល ខ្សែភ្លើងអគ្គិសនី ខ្សែភ្លើងសម្រាប់ទំនាក់ទំនង ឧបករណ៍អគ្គិសនីសម្រាប់សាកអាគុយ អាគុយអគ្គិសនីម៉ាក **Baseus** ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ធី សប ៦.ក** ។

**យោង:**
- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **ធី សប ៦.ក** ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៧
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Shenzhen Times Innovation Technology Co., Ltd ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៧
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៦៥១១៦/១៧ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៧។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលសម្ភារៈ និងគ្រឿងអគ្គិសនីដូចជា៖ ក្បាល(ដុំ)សម្រាប់បំបែក ឬបែងចែក [ឧបករណ៍ដំណើរការទិន្នន័យ] ឧបករណ៍ឆ្លុះអក្សរ និងលេខសម្ងាត់ [ឧបករណ៍ដំណើរការទិន្នន័យ] ឧបករណ៍ផ្ទុកព័ត៌មាន (USB) ឧបករណ៍ជំនួយផ្តិតមេដៃផ្ទាល់ខ្លួន (PDAs) ឧបករណ៍តន្ត្រីអេឡិចត្រូនិច ឧបករណ៍អាចទាញយកព័ត៌មាន សម្ភារៈបិទពីលើសម្រាប់ស្មាតហ្វូន ផ្លាស់ស្ទីកបិទសម្រាប់ការពារស្មាតហ្វូន ធុងបាស កាសស្តាប់ត្រចៀក ឧបករណ៍បង្កូម ឬជួយសម្លេង ឧប្លើរ វ៉ែនតាមើលវីដេអូដូចឃើញរូបភាពពិតៗ ឧបករណ៍សារ៉េសម្លេង ឧបករណ៍ដូត ញុក ខ្នាស់ ថតរូបផ្ទាល់ខ្លួន [ដងកាន់សម្រាប់ថតរូប] ម៉ាស៊ីនថតឃើញ ស្រមោល ខ្សែភ្លើងអគ្គិសនី ខ្សែភ្លើងសម្រាប់ទំនាក់ទំនង ឧបករណ៍អគ្គិសនីសម្រាប់សាកអាគុយ អាគុយអគ្គិសនីពាក់ម៉ាកខាងលើក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **ធី សប ៦.ក** ដែលទទួលបានពីក្រុមហ៊ុន Shenzhen Times Innovation Technology Co., Ltd ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ដែលក្រសួងបានតម្កល់ទុករួចហើយ ។

លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ មានសុពលភាពត្រឹមថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញ មុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Shenzhen Times Innovation Technology Co., Ltd ដែលជាម្ចាស់ម៉ាក ។/.

ចាប់ពីរយៈពេល ៩០(កៅសិប) ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ អ្នកទទួលសិទ្ធិស្របច្បាប់ មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងចំពោះទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះក្នុងទំព័រខាងមុខសារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្ត ជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រាជ្ញា**

*ចម្លងជូន:*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន***
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ*
- *ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *អគ្គនាយកដ្ឋានកាំកុងត្រូល*
- *អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*